កាវិយាល័យរដ្ឋបាល
មកដល់ថ្ងៃទី 25.12.09 ម៉ោង 10 ...
លេខ 10751 ... ស.ឃ.ទ
អ្នកទទួល: ... ហត្ថលេខា ...
អ្នកប្រគល់: ... ហត្ថលេខា ...
បញ្ជូនទៅ ...

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ: ៧០៦៨ ...

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០០៩

## សូមជម្រាបជូន

## ឯកឧត្តម លោកជំទាវ អគ្គនាយករដ្ឋបាល

## គ្រប់ក្រសួងរដ្ឋលេខាធិការដ្ឋាន និងស្ថាប័នរដ្ឋ

**កម្មវត្ថុ** : ករណីលិខិតបទដ្ឋានគតិយុត្ត ដែលស្នើឆ្លងទីស្តីការគណៈរដ្ឋមន្ត្រី ជា Soft Copy ។

**យោង** : -លិខិតលេខ ៨២៧ សជណ.អគ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ របស់ ទីស្តីការគណៈរដ្ឋមន្ត្រី

-សារាចរណែនាំលេខ០១ សរណន ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៩ ស្តីពីការប្រើប្រាស់កម្រងកម្មវិធីពុម្ពអក្សរខ្មែរយូនីកូដ (Khmer-Unicode) របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន ឯកឧត្តម លោកជំទាវ ជ្រាបថាៈ ដើម្បីឱ្យមានលក្ខណៈងាយស្រួល និងឯកភាពគ្នាលើពុម្ពអក្សរ (Font) Computer នោះអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាលស្នើសុំរាល់លិខិតបទដ្ឋានគតិយុត្តទាំងអស់ ដែលត្រូវស្នើសុំដាក់ប្រជុំនៅទីស្តីការគណៈរដ្ឋមន្ត្រី សូមវាយអក្សរខ្មែរយូនីកូដ (Khmer-Unicode) វិញដើម្បីឱ្យដំណើការនៃការផ្លាស់ប្តូរពុម្ពអក្សរ (Font) នេះមានភាពរលូនឆាប់រហ័ស និងអនុវត្តឱ្យបានស៊ីសង្វាក់គ្នា ។ ចំពោះការផ្លាស់ប្តូរវាយពុម្ពអក្សរខ្មែរយូនីកូដ (Khmer-Unicode) នេះ អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាលសូមកំណត់រយៈពេលឱ្យតែ៦០ថ្ងៃប៉ុណ្ណោះ សម្រាប់ក្រសួង-ស្ថាប័នទាំងអស់ធ្វើការរៀបចំ គិតចាប់ពីថ្ងៃនៃការជូនដំណឹងនេះ ។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកជំទាវ មេត្តាសហការចំពោះការផ្លាស់ប្តូរពុម្ពអក្សរ (Font) ទាំងអស់ឱ្យទៅជាពុម្ពអក្សរខ្មែរយូនីកូដ (Khmer-Unicode)វិញ ក្នុងករណីមានការលំបាកលើបញ្ហាបច្ចេកទេសសូមធ្វើការទំនាក់ទំនងជាមួយ NiDA ដើម្បីជួយសម្រួល ។

សូមឯកឧត្តម លោកជំទាវ មេត្តាទទួលនូវការរាប់អានអំពីខ្ញុំ ។

ទីប្រឹក្សារាជរដ្ឋាភិបាល និងជា
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវ តាន់

ចម្លងជូនៈ
- អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍បច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា (NiDA)
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន
- គ្រប់អាជ្ញាធរនិងអង្គភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**លេខៈ** ៨៤៧ សជណ.អគ

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៩

**គោរពជូន**
**ឯកឧត្តម លោកជំទាវ**
**ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន**

**កម្មវត្ថុ**: ការចាត់តំណាងរបស់ក្រសួង ស្ថាប័ន ចូលរួមក្នុងអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតនៅទីស្តីការគណៈរដ្ឋមន្ត្រី។

**យោង** : សារាចរណែនាំលេខ ១៣ សរណន ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០០ របស់រាជរដ្ឋាភិបាល។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន ឯកឧត្តម លោកជំទាវ មេត្តាជ្រាបថា : កន្លងមក ទីស្តីការគណៈរដ្ឋមន្ត្រីបានសង្កេតឃើញមានក្រសួង ស្ថាប័នមួយចំនួន បានខិតខំយកចិត្តទុកដាក់អនុវត្តតាមស្មារតីនៃសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ១៣ សរណន ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីការចាត់តាំងតំណាងរបស់ក្រសួង ស្ថាប័ន ចូលរួមក្នុងកិច្ចប្រជុំនៅទីស្តីការគណៈរដ្ឋមន្ត្រី។ ទន្ទឹមនឹងនេះ ក៏មានក្រសួង ស្ថាប័នមួយចំនួនទៀត នៅពុំទាន់អនុវត្តបានត្រឹមត្រូវតាមស្មារតីនៃសារាចរណែនាំខាងលើនៅឡើយ។

ដើម្បីពង្រឹងយន្តការនៃអង្គប្រជុំលើកទី ១ និងអង្គប្រជុំអន្តរក្រសួង នៅទីស្តីការគណៈរដ្ឋមន្ត្រី ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ សូមឯកឧត្តម លោកជំទាវ មេត្តាជ្រាបនូវគោលការណ៍ ដូចខាងក្រោម ÷

ក- អង្គប្រជុំលើកទី ១ គឺជាការប្រជុំពិគ្រោះយោបល់ ដែលក្រសួង ស្ថាប័នសាមីត្រូវពិភាក្សា ផ្លាស់ប្តូរយោបល់ជាមួយក្រុមប្រឹក្សាអ្នកច្បាប់ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃទីស្តីការគណៈរដ្ឋមន្ត្រី និងអគ្គលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាល ដើម្បីពិនិត្យលើទិដ្ឋភាពនយោបាយ ទិដ្ឋភាពច្បាប់ ទិដ្ឋភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងផ្នែកទម្រង់ ខ្លឹមសារ ពាក្យបច្ចេកទេស អក្ខរាវិរុទ្ធ របស់សេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលក្រសួង ស្ថាប័នសាមីបានស្នើ។ ដើម្បីឱ្យការពិភាក្សាទទួលបានលទ្ធផលល្អ ក្រសួង ស្ថាប័នសាមីត្រូវចាត់តំណាង ថ្នាក់រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ និងមន្ត្រីជំនាញ ដែលមានសមត្ថកិច្ច និងយល់ដឹងច្បាស់អំពីការងារពាក់ព័ន្ធ ទៅចូលរួម ដើម្បីការពារសេចក្តីព្រាងអត្ថបទ ដែលជាសំណើរបស់ក្រសួង ស្ថាប័នផ្ទាល់។

ខ- អង្គប្រជុំអន្តរក្រសួង គឺជាការប្រជុំសម្របសម្រួលមតិយោបល់ របស់ក្រសួង ស្ថាប័នដែលស្នើសេចក្តីព្រាងអត្ថបទ និងក្រសួងស្ថាប័នដែលពាក់ព័ន្ធ។ ដើម្បីឱ្យការងារនេះទទួលបានលទ្ធផលល្អ ក្រសួងស្ថាប័នសាមី និងក្រសួងស្ថាប័ន

ពាក់ព័ន្ធ ត្រូវចាត់តំណាងទៅចូលរួមក្នុងអង្គប្រជុំអន្តរក្រសួង ដើម្បីពិភាក្សា និងសម្រេចសេចក្តីព្រាងអត្ថបទចុងក្រោយ សម្រាប់ដាក់ឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ដូចខាងក្រោម ÷

- ចំពោះក្រសួង ស្ថាប័នសាមី ត្រូវចាត់សមាជិករាជរដ្ឋាភិបាល អមដោយអនុរដ្ឋលេខាធិការ និងមន្ត្រីជំនាញ ដែលមានសមត្ថកិច្ច និងយល់ដឹងច្បាស់អំពីការងារពាក់ព័ន្ធ ទៅចូលរួមជាចាំបាច់ ដើម្បីការពារសេចក្តីព្រាងអត្ថបទឱ្យមានប្រសិទ្ធភាព។

- ចំពោះក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវចាត់តំណាងថ្នាក់រដ្ឋលេខាធិការ ឬ អនុរដ្ឋលេខាធិការ ឬ អគ្គនាយក ដែលមានសមត្ថកិច្ច និងយល់ដឹងច្បាស់អំពីការងារពាក់ព័ន្ធ ទៅចូលរួមប្រជុំ។

ដើម្បីឱ្យការប្រជុំដំណើរការទៅមុខដោយរលូន តំណាងចូលរួមប្រជុំ ត្រូវចូលរួមប្រជុំតាំងពីដើមរហូតដល់ចប់សេចក្តីព្រាងអត្ថបទ។ ក្នុងករណីមានធុរៈមិនអាចចូលរួមប្រជុំបាន តំណាងដែលចូលរួមប្រជុំដំបូងត្រូវរាយការណ៍ និងប្រគល់សេចក្តីព្រាងអត្ថបទ ទៅតំណាងដូចបានកំណត់ខាងលើ ដែលត្រូវទៅប្រជុំបន្ត ដើម្បីជៀសវាងលើកយកបញ្ហាដែលបានឯកភាពគ្នារួចហើយ មកពិភាក្សាម្តងទៀត។

ដើម្បីត្រៀមការប្រជុំឱ្យបានល្អ ក្រសួង ស្ថាប័នសាមីត្រូវបញ្ជូនលិខិតស្នើសុំប្រជុំពិនិត្យសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត សម្រាប់អង្គប្រជុំលើកទី ១ ក៏ដូចជាអង្គប្រជុំអន្តរក្រសួង និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ទៅទីស្តីការគណៈរដ្ឋមន្ត្រី ( អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល) ដោយត្រូវភ្ជាប់ជាមួយនូវឯកសារដូចខាងក្រោម ÷

- ច្បាប់ចម្លងសេចក្តីព្រាងអត្ថបទ ចំនួន ១២០ (មួយរយម្ភៃ) ច្បាប់ ឬ ច្រើនជាងនេះតាមការចាំបាច់ ជាក់ស្តែង ដោយភ្ជាប់សូហ្វកូពី (Soft copy ) ផង។
- ច្បាប់ចម្លងនៃសេចក្តីថ្លែងហេតុ ចំនួន ១២០ ( មួយរយម្ភៃ) ច្បាប់។
- ឯកសារពាក់ព័ន្ធ ដែលមានយោងនៅក្នុងមូលបទ ក្នុងមួយមុខៗ ចំនួន ២០ ( ម្ភៃ) ច្បាប់។

ដើម្បីសម្រួលក្នុងការទាក់ទងការងារ សូមឯកឧត្តម លោកជំទាវ បញ្ជូនឈ្មោះមន្ត្រីទទួលបន្ទុក អាសយដ្ឋានទំនាក់ទំនង និងលេខទូរស័ព្ទ លេខទូរសារ ឬអ៊ីមែលទៅអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល ( ជាន់ទី ២ បន្ទប់លេខ ២១២ ទូរស័ព្ទលេខ ០២៣ ២១៩ ១៦០, ០១២ ៤៥៦ ១៤៦, ០១១ ៩៤៥ ៨៥៣ ) ។

សូមឯកឧត្តម លោកជំទាវ មេត្តាជ្រាប និងអនុវត្តតាមការគួរ ។

សូមឯកឧត្តម លោកជំទាវ មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រ ពីខ្ញុំ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សុខ អាន

*ចម្លងជូន :*

- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ: ០១ សរណន

# សារាចរណែនាំ

## ស្តីពី

## ការប្រើប្រាស់កម្រងកម្មវិធីពុម្ពអក្សរខ្មែរយូនីកូដ (Khmer Unicode)

កន្លងមក អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា (NiDA) បានបង្កើតនូវកម្រងកម្មវិធីពុម្ពអក្សរខ្មែរយូនីកូដមួយ ដែលមានលក្ខណៈងាយស្រួលក្នុងការប្រើប្រាស់។

ទីស្តីការគណៈរដ្ឋមន្ត្រី សូមធ្វើការណែនាំដល់គ្រប់ស្ថាប័ន អង្គភាព និងអាជ្ញាធរក្រោមឱវាទទីស្តីការគណៈរដ្ឋមន្ត្រីទាំងអស់ ត្រូវប្រើពុម្ពអក្សរខ្មែរយូនីកូដ ក្នុងការផលិត និងរៀបចំគ្រប់ឯកសាររដ្ឋបាល ឬលិខិតបទដ្ឋានគតិយុត្តនានា សំដៅឲ្យមានការឯកភាពគ្នា និងជួយសម្រួលការងារនៅក្នុងក្របខ័ណ្ឌទីស្តីការគណៈរដ្ឋមន្ត្រីទាំងមូល។ ចំពោះកម្រងកម្មវិធីគំរូអក្សរខ្មែរយូនីកូដ និងរបៀបប្រើប្រាស់ សូមទាក់ទងជាមួយអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា (NiDA)។

ទទួលបានសារាចរណែនាំនេះ ស្ថាប័ន អង្គភាព និងអាជ្ញាធរនានាក្រោមឱវាទទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវចាត់ចែងអនុវត្តជាកំហិតក្នុងស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៩

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សុខ អាន

កន្លែងទទួល:

- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *គ្រប់ស្ថាប័ន អង្គភាព និងអាជ្ញាធរចំណុះទីស្តីការគណៈរដ្ឋមន្ត្រី*
- *ឯកសារ-កាលប្បវត្តិ*